archive.today webpage capture | Saved from https://cdc.gov.kh/recent-news/គណៈកម្មាធិការវិនិយោគក-30/ search | 2 Feb 2023 10:00:11 UTC
no other snapshots from this url
All snapshots from host cdc.gov.kh
Webpage Screenshot share download .zip report bug or abuse Buy me a coffee

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA



# គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា បានសម្រេចចេញវិញ្ញាបនបត្រចុះបញ្ជីគម្រោងវិនិយោគ ជូនដល់ក្រុមហ៊ុនចំនួន ៥៖




តាមសំណើសុំវិនិយោគរបស់ក្រុមហ៊ុន គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានសម្រេចចេញវិញ្ញាបនបត្រចុះបញ្ជីគម្រោងវិនិយោគជូនដល់ក្រុមហ៊ុនដូចខាងក្រោម៖

១-"GORGEOUS LIGHTS CO., LTD" គម្រោងបង្កើតរោងចក្រផលិតអំពូលភ្លើង អំពូលលម្អ និងគ្រឿងបង្គុំរបស់អំពូលលម្អ ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិព្រៃកទប់ ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ក្នុងទុនវិនិយោគប្រមាណ ៨,១លានដុល្លារអាម៉េរិក និងអាចបង្កើតការងារបានចំនួន ១.០៣៣កន្លែង។

២-"JT ELECTRONICS CO., LTD" គម្រោងបង្កើតរោងចក្រផលិតគ្រឿងអេឡិចត្រូនិកគ្រប់ប្រភេទ អំពូលភ្លើង និងគ្រឿងបង្គុំអំពូលភ្លើង ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិព្រៃកទប់ ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ក្នុងទុនវិនិយោគប្រមាណ ៥,៤លានដុល្លារអាម៉េរិក និងអាចបង្កើតការងារបានចំនួន ៩៨៣កន្លែង។

៣-"LINGBENYANG OPTOELECTRONICS (CAMBODIA) CO., LTD" គម្រោងបង្កើតរោងចក្រផ្គុំដំឡើងអំពូលភ្លើង គ្រឿងអេឡិចត្រូនិក និងគ្រឿងបន្លាស់អេឡិចត្រូនិកគ្រប់ប្រភេទ ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិចមពល ឃុំពេល ស្រុកត្រាំកក់ ខេត្តតាកែវ ក្នុងទុនវិនិយោគប្រមាណ ៥,២លានដុល្លារអាម៉េរិក និងអាចបង្កើតការងារបានចំនួន ១.០៣៣កន្លែង។

៤-"YI ZHOU HONG RI (CAMBODIA) CO., LTD" គម្រោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិម៉ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ក្នុងទុនវិនិយោគប្រមាណ ៥,១លានដុល្លារអាម៉េរិក និងអាចបង្កើតការងារបានចំនួន ៧៤៤កន្លែង។

ដោយឡែក តាមសំណើសុំវិនិយោគរបស់ក្រុមហ៊ុន គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានសម្រេចចេញវិញ្ញាបនបត្រចុះបញ្ជីគម្រោងវិនិយោគ ជូនដល់ក្រុមហ៊ុន "FORESTSTAR TREE INDUSTRIAL (CAMBODIA) CO., LTD." ដែលជាគម្រោងបង្កើតរោងចក្រផលិតដើមឈូអែល អំពូលភ្លើងលម្អដើមឈូអែល សម្ភារៈគ្រប់ប្រភេទសម្រាប់តុបតែងលម្អដើមឈូអែល និងវត្ថុអនុស្សាវរីយ៍ ដែលមានទីតាំងវិនិយោគស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ហាយ ផាក ខេត្តស្វាយរៀង ក្នុងទុនវិនិយោគប្រមាណ ៥,៤លានដុល្លារអាម៉េរិក និងអាចបង្កើតការងារបានចំនួនប្រមាណ ៧៦៨កន្លែង។

រូបភាពផលិតផលក្រុមហ៊ុន YI ZHOU HONG RI (CAMBODIA) CO., LTD.



**WHY CAMBODIA**

- Conducive Investor Climate
- Competitive Workforce
- Connecting Trade Infrastructure
- Consistent, Sustainable Growth

**PRIORITY SECTORS**

- Agri-Food
- Automtive
- Electronics
- Textile and Apparel
- Bike & Parts
- Furniture & Plywood

**INVESTOR'S INFORMATION**

- Recent News
- Laws and Regulations
- Step by Step Guide
- Incentives and Schemes
- Special Economic Zones
- Industrial Development Policy

**INVESTMENT SERVICES**

- Application Form
- Checklist
- Service Fee

**ABOUT US**

- Contact Us
- Who We Are
- Management

© Copyright by CDC រក្សាសិទ្ធិដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា